**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ឧត្តមក្រុមប្រឹក្សា កំណែទំរង់រដ្ឋ**

**ក្រុមប្រឹក្សាគោលនយោបាយដីធ្លី**

លេខ..១៤ សសរ..

រាជធានីភ្នំពេញ ថ្ងៃទី..១៥...ខែ..ឧសភា....ឆ្នាំ ២០០៤

## សេចក្តីសំរេច

## ស្តីពី

## ការតែងតាំងមន្ត្រីបំរើការងាររៀបចំគំរោងបែងចែកដីធ្លី សំរាប់សង្គមកិច្ច និងអភិវឌ្ឍន៍សេដ្ឋកិច្ច

## ( LASED )

## ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី

- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៤០៥ អនក្រ.តត ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៩៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- យោងតាមការចាំបាច់

## សំរេច

**ប្រការ១ :** ត្រូវបានចាត់តាំងមន្ត្រីដើម្បីរៀបចំគំរោងបែងចែកដីធ្លីសំរាប់សង្គមកិច្ច និងអភិវឌ្ឍន៍សេដ្ឋកិច្ច "Land Allocation for Social and Economic Development" (LASED) ដែលមានរាយនាមដូចខាងក្រោម :

១-លោក **សរ សុវណ្ណ** អគ្គនាយករង នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងជានាយកគំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី បំរើការជានាយកថ្នាក់ជាតិរៀបចំគំរោង ។

២-លោក **សារេត បូរាមី** អនុប្រធាននាយកដ្ឋានស្រាវជ្រាវ និងបទប្បញ្ញត្តិ និងជាប្រធានផ្នែកផែនការថវិកា និងតាមដានការងារ បំរើការជាប្រធានក្រុមការងារថ្នាក់ជាតិរៀបចំគំរោង ។

**ប្រការ២** : នាយកខុទ្ទកាល័យ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាគោលនយោបាយដីធ្លី អគ្គនាយក គ្រប់អគ្គនាយកដ្ឋាន នាយកគំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី គ្រប់ប្រធាននាយកដ្ឋាន នាយកចាត់ការគំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីខេត្ត-ក្រុង និងអស់លោកដែលមានឈ្មោះដូចមានចែងក្នុងប្រការ១ មានភារកិច្ចអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី

អ៊ឹម ឈុនលិម

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សមាជិកក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- ដូចប្រការ ២
- ឯកសារ-កាលប្បវត្តិ